# មេរៀនទី ៤៦: ផារ៉ោនឱ្យយ៉ូសែបធ្វើជាអ្នកគ្រប់គ្រង

## លោកុប្បត្តិ ៣៩:២០-៤១:៤៩

**គោលបំណង៖** ព្រះអង្គចង់ឱ្យយើងបំរើទ្រង់។

**ខគម្ពីរចងចាំ៖ កូល៉ុស ៣:២៣** "*ហើយការអ្វីដែលត្រូវធ្វើក៏ដោយ ចូរធ្វើឲ្យអស់ពីចិត្ត ទុកដូចជាធ្វើថ្វាយដល់ព្រះអម្ចាស់ មិនមែនដល់មនុស្សទេ។*"

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
នៅពេលយើងស្រលាញ់និងបំរើព្រះ នឹងជួយចម្រើនកម្លាំងដល់យើង ហើយកាន់តែធ្វើឱ្យយើងដូចជាព្រះគ្រីស្ទថែមទៀតផង។ ព្រះប្រើការរីកចម្រើនរបស់គ្រីស្ទបរិស័ទ ដើម្បីជម្រុញឱ្យមានការផ្លាស់ប្តូរទៅកាន់មនុស្សដទៃនៅគ្រប់ទីកន្លែង។ យ៉ូសែបបាននាំឱ្យមានការផ្លាស់ប្តូរ បើទោះបីជាគាត់ស្ថិតបរិបទចម្លែក និង លំបាកយ៉ាងណាក៏ដោយ។ តើអ្នកយល់ថាអ្នកបាននាំការផ្លាស់ប្តូរសំរាប់ជីវិតសិស្សៗរបស់អ្នកដែរឬទេ? សូមចំណាយពេលស្ងៀមស្ងាត់ ហើយអធិស្ឋានជាមួយពាក្យទាំងនេះ "ព្រះយេស៊ូវសូមជួយកូនឱ្យយល់ពីសារៈសំខាន់នៃការដឹកនាំសិស្សទាំងអស់។ អរព្រះគុណទ្រង់ដែលបានប្រើកូនដើម្បីជួយឱ្យពួកគេកាន់តែខិតជិតព្រះអង្គ! អាម៉ែន"

**ចំរៀង៖** ១. គឺជាការល្អដែលសរសើរព្រះ ២.ចូរសរសើរព្រះយេស៊ូវ ៣. បើទ្រង់គង់ជាមួយ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ត្រូវបំរើព្រះដោយអស់ពីចិត្តរបស់យើង»**

**សម្ភារៈដែលត្រូវការ៖** បោះពុម្ពរូបបេះដូង រួចកាត់ពាក់កណ្តាល (សូមមើលរូបខាងក្រោមដើម្បីបោះពុម្ព)
១. នៅពេលដែលយើងបំរើព្រះ ព្រះអង្គចង់ឱ្យយើងបំរើទ្រង់ដោយអស់ពីចិត្ត។
២. នៅក្នុងក្រដាសដែលមានរូបបេះដូងនៅខាងក្រោម សូមកាត់រូបបេះដូងនីមួយៗជាពីរចំណែកស្មើគ្នា។
៣. ពេលភ្លេងចាប់ផ្តើមលេង សូមចែកបំណែកបេះដូងម្ខាងៗនោះទៅកូនសិស្សម្នាក់មួយបំណែកឲ្យបានគ្រប់ៗគ្នា រួចឲ្យពួកគេដើរស្វែងរកបេះដូងមួយបំណែកទៀតដែលជាគូជាមួយបេះដូងដែលគេមាន។



៤. អ្នកណាដែលរកឃើញដៃគូហើយពួកគេអាចអង្គុយចុះបាន។
៥.តើព្រះចង់ឱ្យយើងជាបេះដូងមួយចំហៀង *(លើករូបបេះដូង១ចំហៀងនោះឡើងលើ)* ឬជាបេះដូងមួយដែលពេញលេញ?*(លើកបេះដូង១ចំហៀងទៀតមកផ្គុំគ្នា)*។
៦.ព្រះសប្បាយព្រះទ័យនៅពេលដែលយើងបំរើទ្រង់ ហើយព្រះអង្គកាន់តែសព្វព្រះហឫទ័យនៅពេលដែលយើងបំរើទ្រង់ឱ្យអស់ពីចិត្ត។
ឥលូវនេះយើងនឹងទៅសិក្សាជាមួយគ្នាពីបុរសម្នាក់នៅក្នុងព្រះគម្ពីរដែលគាត់បានបម្រើព្រះដោយអស់ពីចិត្ត។

## ៤. ការណែនាំមេរៀន

សាច់រឿងនៅក្នុងព្រះគម្ពីរនៅថ្ងៃនេះគឺប្រាប់យើងពីយ៉ូសែបបានបំរើ និងថ្វាយបង្គំព្រះមិនថានៅកន្លែងណានោះទេ។ គាត់បានបំរើព្រះដោយអស់ពីចិត្ត ពីព្រោះគាត់ដឹងថាព្រះស័ក្តិសមទទួលការបំរើរបស់គាត់។ យ៉ូសែបត្រូវបានបងរបស់គាត់លក់ឱ្យធ្វើជាទាសករនៅប្រទេសអេស៊ីបដោយសារតែពួកគេស្អប់គាត់។ នៅពេលមួយ យ៉ូសែបបានក្លាយជាទាសកររបស់មេទ័ពធំម្នាក់នៅអេស៊ីព្ទ។ គាត់បានប្រឹងប្រែងធ្វើការដោយស្មោះត្រង់ និងអស់ចិត្តរបស់គាត់។ គាត់ត្រូវបានចៅហ្វាយឱ្យតម្លៃ និងទុកចិត្ត រហូតធ្វើឱ្យគាត់បានក្លាយជាអ្នកត្រួតត្រាលើផ្ទះ និងទ្រព្យសម្បត្តិទាំងអស់ដែលចៅហ្វាយមាន។ បន្ទាប់មកមានមនុស្សនិយាយបង្ខូចយ៉ូសែប ហើយគាត់ត្រូវបានគេយកទៅដាក់គុកទាំងដែលគ្មានកំហុសអ្វីសោះ។ តើអ្នកគិតថានឹងមានអ្វីកើតឡើងចំពោះយ៉ូសែបក្រោយមកនោះ?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងគុកយ៉ូសែបតែងចងចាំថាព្រះទ្រង់គង់ជាមួយគាត់គ្រប់ពេល។ គាត់បានទុកចិត្តព្រះហើយធ្វើអ្វីដែលត្រឹម-ត្រូវ ទោះបីជាអ្នកដទៃប្រព្រឹត្តិបែបណាដាក់គាត់ក៏ដោយ។ យ៉ូសែបក៏បានជួយដល់អ្នកទោសផ្សេងទៀតផងដែរ គាត់ដឹងថាព្រះស័ក្តិសមទទួលនូវការបម្រើទ្រង់ដោយអស់ពីចិត្ត បើទោះបីជាមានរឿងអ្វីក៏ដោយ ក៏យ៉ូសែបនៅតែជ្រើសរើសធ្វើនូវអ្វីដែលត្រឹមត្រូវ។ ថ្ងៃមួយយ៉ូសែបត្រូវបានគេហៅទៅក្នុងវាំង ដើម្បីជួយកាត់សុបិន្តរបស់ស្តេចផា-រ៉ោន។ ដោយសារមានជំនួយពីព្រះ យ៉ូសែបអាចបកស្រាយសុបិន្តរបស់ផារ៉ោន ដោយស្រាយថានឹងមានភាពសំបូរសប្បាយ៧ឆ្នាំ និង៧ឆ្នាំទៀតមានគ្រោះទុរ្ភិក្ស។ យ៉ូសែបបំរើព្រះដោយក្តីជំនឿ ហើយមនុស្សដទៃក៏មើលឃើញវត្តមានរបស់ព្រះគង់នៅជាមួយគាត់ដែរ។ ផារ៉ោនពេញចិត្តនឹងយ៉ូសែបណាស់ ហើយបានហៅគាត់មករស់នៅក្នុងរាជវាំង។ ទោះជាយ៉ូសែបគ្មានសេរីភាព តែគាត់ក៏មិនបានជាប់នៅក្នុងគុកទៀតដែរ។ មិនយូរប៉ុន្មានផារ៉ោនបានលើកយ៉ូសែបឱ្យធ្វើជាមេបញ្ជាការទី២ប្រចាំប្រទេស នេះគឺមានន័យថាយ៉ូសែបមានអំណាចជាងមនុស្សគ្រប់គ្នានៅអេស៊ីព្ទ លើកលែងតែផារ៉ោនម្នាក់ប៉ុណ្ណោះ។

អ្វីដែលធ្វើឱ្យយ៉ូសែបកាន់តែអស្ចារ្យទៀតនោះគឺគាត់បំរើព្រះគ្រប់កាលៈទេសៈ បើទោះជាអ្នកដទៃធ្វើអាក្រក់ឬធ្វើល្អដាក់គាត់ក៏ដោយ។ យ៉ូសែបបានធ្វើតាមអ្វីដែលមាននៅក្នុងខគម្ពីរចងចាំរបស់យើងថ្ងៃនេះដែលបានចែងថា ៖ មិនថាគាត់ធ្វើអ្វីនោះទេ គឺគាត់អស់ពីចិត្តសម្រាប់ព្រះជាម្ចាស់។ យ៉ូសែបមិនបានព្យាយាមធ្វើឱ្យអ្នកមើលការខុសត្រូវក្នុងគុក ឬ ផារ៉ោនសប្បាយចិត្តនោះទេយ៉ូ តែគាត់បានបំរើព្រះដោយអស់ពីចិត្តរបស់គាត់។ ព្រះជាម្ចាស់ទ្រង់ស្រលាញ់ការបំរើរបស់យ៉ូសែប ហើយព្រះអង្គបានប្រទានពរ និង សេចក្តីសុខសាន្តដល់គាត់។ យើងត្រូវតែបំរើព្រះដោយអស់ពីចិត្តដូចយ៉ូសែបអញ្ចឹងដែរ!

## ៦. សំនួរពិភាក្សា

១.ហេតុអីបានជាយ៉ូសែបជាប់គុក? *មានអ្នកនិយាយបង្ខូចគាត់*

២.តើនៅក្នុងគុកយ៉ូសែបបំរើព្រះដោយរបៀបណា?*ដោយចិត្ត ឬ បេះដូងរបស់គាត់*

៣.តើយ៉ូសែបជួយផារ៉ោនយ៉ាងដូចម្តេច? *យ៉ូសែបកាត់ស្រាយសុបិន្តរបស់ផារ៉ោន*

៤.តើផារ៉ោនបានយល់សប្តិឃើញអ្វី?

*គាត់ឃើញគោស្គម៧ លេបគោធាត់៧ ហើយគួរស្រូវ៧ធំ ថ្លោសៗត្រូវស្រូវតូចៗស្កក ៧លេប*

៥.តើអ្នកគិតថាអ្នកអាចបំរើព្រះដោយចេញពីចិត្តរបស់អ្នកដែរឬទេ បើទោះជាពេលខ្លះមានការអាក្រក់កើតឡើងចំពោះអ្នកក៏ដោយ? *ចាំស/បាទ យើងគួរតែទុកចិត្តព្រះគ្រប់ពេល*

## ៧. ខគម្ពីរចងចាំ      កូល៉ុស ៣:២៣




ដើម្បីជួយឱ្យកុមារឆាប់ចងចាំ ( ដោយប្រើបាតដៃ) របៀធ្វើ៖ ឱ្យកុមារគូរផ្តាមបាតដៃនៅលើក្រដាស បន្ទាប់មកកាត់រូបបាតដៃនោះ ហើយសរសេរឃ្លានៅក្នុងខគម្ពីរដាក់នៅលើម្រាមដៃនីមួយៗ។ សូមមើលលើរូបភាពបាតដៃដែលបានសរសេរខគម្ពីរជាឧទាហរណ៍នៅស្តាំនេះ។

## ៨. ហត្ថកម្ម



បោះពុម្ពរង្វង់ខ្សែបូ ហើយឱ្យកុមារកាត់វាចេញមកហើយផាត់ពណ៌ដោយខ្លួនឯង។ ឱ្យសិស្សសរសេរឈ្មោះពួកគេនៅក្នុងរង្វង់ ហើយសរសេរ “ បំរើព្រះ” នៅលើខ្សែបូមួយ និង “ អស់ពីចិត្តខ្ញុំ” នៅលើខ្សែបូមួយទៀត។

**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*









